ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តក្រចេះ
ក្រុមលទ្ធកម្ម
លេខៈ០.០២/១៨ កប.ក្រច.ក.ល

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

សេចក្តីជូនដំណឹង

ជួសជុលពង្រីកអគាររដ្ឋបាល និងសាលប្រជុំ គម្រោងពីរជាន់ដំណាក់កាលបញ្ចប់ និងជួសជុលរបងថ្មក្បាច់ និងក្លោងទ្វារខាងមុខ និងរបងឃ្លុបចំហៀង និងក្រោយប្រវែង ៦៥ម៉ែត្រ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តក្រចេះ សម្រាប់ឆ្នាំ២០១៨

មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តក្រចេះ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើស "អ្នកទទួលការ" ធ្វើការងារជួសជុលពង្រីកអគាររដ្ឋបាល និងសាលប្រជុំ គម្រោងពីរជាន់ដំណាក់កាលបញ្ចប់ និងជួសជុលរបងថ្មក្បាច់ និងក្លោងទ្វារខាងមុខ និងរបងឃ្លុបចំហៀង និងក្រោយប្រវែង ៦៥ម៉ែត្រ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តក្រចេះ សម្រាប់ឆ្នាំ២០១៨។

មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ។

ឯកសារដេញថ្លៃមានដាក់លក់នៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ដែលមានអាសយដ្ឋានសង្កាត់អូឬស្សី ក្រុងក្រចេះ ខេត្តក្រចេះ ចាប់ពីថ្ងៃទី ២៦ ខែមីនា ឆ្នាំ២០១៨ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ 088860 1544)។

ឯកសារដេញថ្លៃដែលបានបំពេញរួចត្រូវប្រគល់ជូនក្រុមលទ្ធកម្មមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តក្រចេះ យ៉ាងយូរបំផុតត្រឹមថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨ វេលាម៉ោង១៥:៣០។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត តាមអាសយដ្ឋានខាងលើ វេលាម៉ោង១៥:៣០ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ២០១៨ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃសូមអញ្ជើញទាក់ទងជាមួយក្រុមលទ្ធកម្មនៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃចន្ទ ១២កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស២៥៦១
ធ្វើនៅក្រចេះ ថ្ងៃទី២៦ ខែ ០៣ គ.ស២០១៨
ប្រធានមន្ទីរ និងជាប្រធានក្រុមលទ្ធកម្ម

កែវ.កុសល

ចម្លងជូន ៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ "កាលប្បវត្តិ"

៤